**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ : ០៣៥ គ.ជ.ប. ស.ណ.វ

# សេចក្តីណែនាំ

# ស្តីពី

# ការហែក្បួនឃោសនាបោះឆ្នោត និងការធ្វើសកម្មភាពចែកខិត្តបណ្ណនៅក្នុងផ្សារ របស់គណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ) និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ (ប.ន.ត.រ) ក្នុងគោលបំណងឱ្យដំណើរការនៃការឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅបានត្រឹមត្រូវ ធានាបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ល្អ បញ្ចៀសការកកស្ទះចរាចរណ៍តាមដងផ្លូវ ទីប្រជុំជន និងទីសាធារណៈ គោរពតាមវិធាននៃបទប្បញ្ញត្តិ និងគោលការណ៍ណែនាំដូចមានចែងក្នុង ច.ប.ត.រ ប.ន.ត.រ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការណែនាំដល់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អាជ្ញាធរមានសមត្ថកិច្ច និងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត អំពីការហែក្បួនឃោសនាបោះឆ្នោត និងសកម្មភាពចែកខិត្តបណ្ណនៅតាមផ្សារក្នុងអំឡុងពេលឃោសនាបោះឆ្នោត ដូចខាងក្រោម៖

## I. ការកំណត់ទម្រង់ និងទំហំនៃការហែក្បួនឃោសនាបោះឆ្នោត

ការហែក្បួនឃោសនាបោះឆ្នោត សំដៅដល់ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ដែលរៀបចំឡើងដោយគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត។

ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ទម្រង់ និងទំហំដូចខាងក្រោម៖

- មានការរៀបចំជាក្បួន មានបិទបដា ឬ/និងពាក្យស្លោក ឬ/និងសារនយោបាយផ្សេងៗ ភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយាន គ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង
- មានអ្នកចូលរួមចាប់ពី ២០ (ម្ភៃ) នាក់ឡើងទៅ ដោយក្រុមថ្មើរជើង ឬ/និងប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ក្នុងការឃោសនាបោះឆ្នោត មានដូចខាងក្រោម៖

- រថយន្តចាប់ពី ២ (ពីរ) គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និង ត្រីចក្រយានយន្តចាប់ពី ១០ (ដប់) គ្រឿងឡើងទៅ
- ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ២០ (ម្ភៃ) គ្រឿងឡើងទៅ
- ជលយានគ្រប់ប្រភេទចាប់ពី ៥ (ប្រាំ) គ្រឿងឡើងទៅ។

ក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានធ្វើយ៉ាងច្រើន ៤ (បួន) ដងក្នុងព្រំប្រទល់រាជធានី ខេត្តដែលសាមីគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

ការហែក្បួនឃោសនាបោះឆ្នោតក្រៅមណ្ឌលបោះឆ្នោត មិនត្រូវបានអនុញ្ញាតឡើយ។ គណបក្សនយោបាយដែលហែក្បួនឃោសនាបោះឆ្នោតក្នុងរាជធានី ខេត្តដែលខ្លួនមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយតម្រាយផ្លូវនៃក្បួនឃោសនានោះ ត្រូវឆ្លងកាត់រាជធានី ខេត្តដទៃ ដោយសារស្ថានភាពទីតាំងភូមិសាស្ត្រជាក់ស្តែងនៃរាជធានី ខេត្តនោះមានព្រំប្រទល់ជាប់គ្នា ដែលមិនអាចវាងបាន គណបក្សនយោបាយសាមីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ខប ពាក់ព័ន្ធ យ៉ាងតិចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនា ទោះបីជារាជធានី ខេត្តដែលត្រូវឆ្លងកាត់នោះ ខ្លួនមាន ឬគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក៏ដោយ។ ក្នុងដំណើរឆ្លងកាត់នេះ សាមីគណបក្សនយោបាយត្រូវបិទឧបករណ៍បំពងសំឡេង និងផ្អាករាល់សកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន។ គធ.ខប ពាក់ព័ន្ធត្រូវស្នើសុំកិច្ចសហការ និងសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចាត់វិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងពេលឃោសនាបោះឆ្នោត។

## II. ការជូនដំណឹងអំពីការហែក្បួនឃោសនាបោះឆ្នោត និងធ្វើសកម្មភាពក្នុងផ្សារ

### ១. ការជូនដំណឹងអំពីការហែក្បួនឃោសនាបោះឆ្នោត

គណបក្សនយោបាយដែលមានបំណងហែក្បួនឃោសនាបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) យ៉ាងតិចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនាបោះឆ្នោត។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី៖

- នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ
- កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន
- ទីតាំងប្រមូលផ្តុំ តម្រាយផ្លូវដែលត្រូវហែក្បួន និងទីតាំងរំសាយ
- ចំនួនអ្នកចូលរួម
- ចំនួនយានជំនិះតាមប្រភេទនីមួយៗ។

### ២. ការជូនដំណឹងអំពីការធ្វើសកម្មភាពចែកខិត្តបណ្ណនៅក្នុងផ្សារ

គ្រប់គណបក្សនយោបាយទាំងអស់ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត ហើយដែលមានបំណងធ្វើសកម្មភាពចែកខិត្តបណ្ណនៅក្នុងផ្សារ សាមីគណបក្សនយោបាយនោះ ត្រូវស្នើសុំទៅអ្នកគ្រប់គ្រងផ្សារ និងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ពាក់ព័ន្ធ យ៉ាងតិចណាស់ឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃធ្វើសកម្មភាព។ ក្នុងការជូនដំណឹងនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី៖

- នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ

- កាលបរិច្ឆេទ ពេលវេលា និងឈ្មោះផ្សារដែលត្រូវធ្វើសកម្មភាព
- ចំនួនអ្នកចូលរួម។

ការធ្វើសកម្មភាពក្នុងផ្សារ ត្រូវកម្រិតយ៉ាងច្រើនត្រឹមតែ ១០ (ដប់) នាក់ ប៉ុណ្ណោះ ហើយត្រូវយកចិត្តទុកដាក់គោរព និងរក្សាឱ្យបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងមិនត្រូវយកតាមខ្លួននូវឧបករណ៍បំពងសំឡេងឡើយ។

ការផ្សព្វផ្សាយតាមឧបករណ៍បំពងសំឡេងអំពីគោលនយោបាយ ឬ/និងកម្មវិធីនយោបាយ ឬ/និងសារនយោបាយរបស់គណបក្សនយោបាយអាចធ្វើបាននៅក្រៅបរិវេណផ្សារ។

គឃ.សប ត្រូវសហការសម្របសម្រួលជាមួយអាជ្ញាធរដែនដី អ្នកគ្រប់គ្រងផ្សារ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការធ្វើសកម្មភាពនោះ។

## III. អំពីកិច្ចសហការ និងការអនុវត្ត

គធ.ខប ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការកំណត់ពីទីសាធារណៈប្រើប្រាស់សម្រាប់ការឃោសនាបោះឆ្នោត ដោយត្រូវយកចិត្តទុកដាក់លើកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ប្រជាពលរដ្ឋទូទៅ។

គណបក្សនយោបាយ ត្រូវប្រមូលយកមកវិញនូវបណ្ណប្រកាស ឬបណ្ណបិទផ្សាយ បដា ឯកសារឃោសនាបោះឆ្នោតទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។

គណបក្សនយោបាយ ត្រូវយកចិត្តទុកដាក់គោរព និងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់ល្អតាមដងផ្លូវ ទីប្រជុំជន ទីសាធារណៈ និងត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការ គ.ជ.ប ប្រធាន គធ.ខប ប្រធាន គឃ.សប អាជ្ញាធរមានសមត្ថកិច្ច និងគណបក្សនយោបាយពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់សហការអនុវត្តឱ្យមានប្រសិទ្ធភាព និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១១រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប និងផ្តល់កិច្ចសហការ"
- ឯកសារកាលប្បវត្តិ